# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៤

## ជប៉ុនផ្តល់ថវិកាសរុបចំនួន ២៧២,៨៧៧ ដុល្លារអាមេរិក សម្រាប់ អនុវត្តគម្រោងចំនួនបី



ក្រោមគ្រោងការណ៍នៃកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចរបស់ជប៉ុន ជំនួយឧបត្ថម្ភឥតសំណងសម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ(ជំនួយគូសាណូណិ) រដ្ឋាភិបាលជប៉ុន បានផ្តល់ទឹកប្រាក់សរុបចំនួន ២៧២,៨៧៧ដុល្លារអាមេរិក ដល់អង្គភាពទទួលជំនួយចំនួនបី។ កិច្ចសន្យាផ្តល់ជំនួយត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ ឯកអគ្គរាជទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និងអ្នកតំណាងមកពីអង្គភាពទទួលជំនួយចំនួនបីដែលនឹងអនុវត្តគម្រោងដូចខាងក្រោម៖



1) គម្រោងសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាបឹងធុង ក្នុងស្រុកបវេល ខេត្តបាត់ដំបង (ថវិកាចំនួន ៨៨,០៣៤ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយៈ មន្ទីរអប់រំ យុវជន និងកីឡាខេត្តបាត់ដំបង។

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាមួយដែលបំពាក់ដោយគ្រឿងសង្ហារឹមសាលារៀន និងបង្គន់អនាម័យនៅសាលាបឋមសិក្សាបឹងធុង ខេត្តបាត់ដំបង។ ក្រោមគម្រោងនេះ សិស្សានុសិស្សប្រមាណជាង៣០០នាក់ នឹងសប្បាយរីករាយក្នុងការសិក្សាក្នុងថ្នាក់រៀនដែលប្រកបដោយសុវត្ថិភាព និងផាសុខភាព។

2) គម្រោងសាងសង់អាគារសិក្សា នៅសាលាបឋមសិក្សាទួលគ្រោះ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ (ថវិកាចំនួន ៨៦,០០៥ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយៈ អង្គការកម្ពុជាដើម្បីកុមារនិងការអភិវឌ្ឍន៍។

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាបេតុងមួយដែលបំពាក់ដោយគ្រឿងសង្ហារឹមសាលារៀន និងបង្គន់អនាម័យ នៅសាលាបឋមសិក្សាទួលគ្រោះ ខេត្តពោធិ៍សាត់។ គម្រោងនេះ នឹងអនុញ្ញាតអោយសិស្សានុសិស្សប្រមាណជាង១៤០នាក់អាចសិក្សាក្នុងបរិស្ថានអប់រំដែលមានលក្ខណៈប្រសើរឡើង។





3) គម្រោងសាងសង់អគារសិក្សា នៅសាលាបឋមសិក្សាបឹងត្នោត ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់(ថវិកាចំនួន ៩៨,៨៣៨ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយៈ បណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់កាត់បន្ថយភាពក្រីក្រ និងអភិវឌ្ឍន៍សង្គម។

គម្រោងនេះ គឺដើម្បីសាងសង់អគារសិក្សាមួយនិងបង្គន់អនាម័យ នៅសាលាបឋមសិក្សាបឹងត្នោត ខេត្តពោធិសាត់។ ក្រោមគម្រោងនេះ សិស្សានុសិស្សប្រមាណជាង៤៣០នាក់ នឹងទទួលបានការសិក្សាក្នុងថ្នាក់រៀនដែលប្រកបដោយសុវត្ថិភាព និងផាសុខភាព។

ជំនួយឥតសំណង *គូសាណូណេ* របស់ជប៉ុនបានចាប់ផ្តើមនៅប្រទេសកម្ពុជានៅឆ្នាំ១៩៩១ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ និងស្តាបនាប្រទេសឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ គម្រោងជំនួយនេះមានទិសដៅការពារជនងាយរងគ្រោះពីកត្តាមួយចំនួនដូចជា ភាពក្រីក្រ និងភាពអកុសលដែលអាចគំរាមកំហែងដោយផ្ទាល់ដល់ជីវភាពរស់នៅ ការចិញ្ចឹមជីវិត និងសេចក្តីថ្លៃថ្នូររបស់ពួកគេ ក៏ដូចជាជួយជំរុញនូវភាពម្ចាស់ការលើខ្លួនឯងរបស់ប្រជាសហគមន៍។ ចាប់តាំងពីឆ្នាំ១៩៩១ រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥២.៣លានដុល្លារអាមេរិកដល់អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលដើម្បីអនុវត្តគម្រោងចំនួន៥២២ គម្រោងនៅទូទាំងប្រទេស។



*ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា*
*ទូរស័ព្ទ: ០២៣-២១៧-១៦១ ទូរសារ: ០២៣-២១៤-៣៣០*
*អ៊ីមែល: eco.jpn@pp.mofa.go.jp*
*គេហទំព័រ: http://www.kh.emb-japan.go.jp*